ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៧៧ ប្រក. កសក

# ប្រ កា ស
# ស្តីពី
# ការកំណត់តំបន់ជំងឺផ្តាសាយបក្សី

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ
- យោងលទ្ធផលវិភាគលេខ៥៦១/១៥ វ.ជ.ស.ប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១** : ត្រូវបានកំណត់តំបន់ជំងឺផ្តាសាយបក្សីចំនួន០១ (មួយ)កន្លែង នៅភូមិជង្គត់ធ្នង់ ឃុំតាគ្រាម ស្រុកបាណន់ ខេត្តបាត់ដំបង។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

**ប្រការ២** : នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ត្រូវចាត់វិធានការបសុពេទ្យនៅតំបន់ផ្ទុះជំងឺផ្តាសាយបក្សី ដែលមានចែងក្នុងប្រការ១ នៃប្រកាសនេះ ដូចខាងក្រោម៖
- បំផ្លាញចោលចំពោះបក្សីឈឺនិងឆ្លងជំងឺនៅក្នុងតំបន់ផ្ទុះជំងឺទៅតាមវិធាននិងបច្ចេកទេសបសុពេទ្យ
- ត្រួតពិនិត្យលើការទិញ លក់ ឬការដឹកជញ្ជូនចំពោះបក្សីគ្រប់ប្រភេទចូល ចេញ ឬឆ្លងកាត់ក្នុងរង្វង់កាំប្រវែង០៣(បី) គីឡូម៉ែត្រពីចំណុចផ្ចិតនៃតំបន់ផ្ទុះជំងឺ។ តំបន់នេះជាតំបន់ត្រួតពិនិត្យ តាមដាន និងសិក្សាស្រាវជ្រាវប្រភពជំងឺផ្តាសាយបក្សីក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ និងត្រួតពិនិត្យចលនាបក្សីជាប្រចាំក្នុងរង្វង់ដែលមានកាំប្រវែង១០(ដប់)គីឡូម៉ែត្រ ពីចំណុចផ្ចិតនៃតំបន់ផ្ទុះជំងឺ។

**ប្រការ៣** : ការរំសាយតំបន់ជំងឺផ្តាសាយបក្សីត្រូវកំណត់ដោយប្រកាសជាថ្មី។

**ប្រការ៤** : ជនណាប្រព្រឹត្តល្មើសនឹងប្រការ២ និងប្រការ៣ នៃប្រកាសនេះត្រូវផ្តន្ទាទោសតាមមាត្រា៣១ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ។

**ប្រការ៥** : ប្រកាសឬសេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល និងប្រធានមន្ទីរកសិកម្មខេត្តបាត់ដំបង ត្រូវទទួលខុសត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត វ៉េង សាខុន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងបរិស្ថាន
- ក្រសួងសុខាភិបាល
- ក្រសួងព័ត៌មាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ